# សេចក្តីថ្លែងការណ៍រួម

# អ្នកសារព័ត៌មានគួរតែមានសេរីភាព មិនរងការគំរាមកំហែង ដើម្បីបំពេញការងារជាដៃគូមិនអាចខ្វះបាននិងប្រកបដោយប្រសិទ្ធភាពជាមួយនឹងរដ្ឋាភិបាល

ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០២១ -- យើងខ្ញុំទាំងអស់គ្នាតំណាងឱ្យអង្គការ សមាគមសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល បណ្តាញអ្នកសារព័ត៌មានដែលមានរាយនាមខាងក្រោម ទទូចជាថ្មីទៀតទៅប្រមុខដឹកនាំរដ្ឋាភិបាលឱ្យណែនាំទៅមន្ត្រី និងអាជ្ញាធរមូលដ្ឋាន ហើយចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីបញ្ឈប់នូវសកម្មភាពគំរាមកំហែង ប្រមាថ និងការរឹតត្បិតទាំងឡាយប្រឆាំងអ្នកសារព័ត៌មានដែលបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈ។ នៅក្នុងសារលិខិតរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់អ្នកសារព័ត៌មានក្នុងទិវាសេរីភាពសារព័ត៌មានពិភពលោក កាលពីថ្ងៃទី៣ ខែឧសភាថ្មីៗនេះ បានបញ្ជាក់ថា វិស័យសារព័ត៌មានកាន់តែមានសារសំខាន់ថែមទៀតក្នុងការបម្រើផលប្រយោជន៍សាធារណជន និង ការផ្សាភ្ជាប់ទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការនាំយកព័ត៌មានពីរដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ ព្រមទាំងនាំយកព័ត៌មាននិងសេចក្តីត្រូវការពីប្រជាពលរដ្ឋមកកាន់រដ្ឋាភិបាលវិញ ដើម្បីដោះស្រាយបញ្ហាបានទាន់សភាពការណ៍ដែលបង្ហាញឱ្យឃើញថា ស្ថាប័នសារព័ត៌មានគឺជាដៃគូមិនអាចខ្វះបានរបស់រដ្ឋាភិបាល។ ទោះជាមានការបញ្ជាក់ពីជំហររបស់ប្រមុខដឹកនាំរដ្ឋាភិបាលយ៉ាងនេះក្តី មន្ត្រីនៅថ្នាក់ក្រោមហាក់មិនបានគោរពអនុវត្តតាម និងកំពុងធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃភាពជាដៃគូរវាងរដ្ឋាភិបាលនិងអ្នកសារព័ត៌មាន។

ជាក់ស្តែងអ្នករាយការណ៍ព័ត៌មានវីអូឌី លោក យុត សុគន្ធ ត្រូវបានអាជ្ញាធរខេត្តពោធិ៍សាត់ដកយកសម្ភារ និងហាមឃាត់មិនឱ្យថតរូប អំឡុងពេលលោកចុះយកព័ត៌មានរឿងពលរដ្ឋនៅខេត្តកំពង់ឆ្នាំងតវ៉ាបិទកំណាត់ផ្លូវជាតិលេខ៥ ដែលជាប់ព្រំប្រទល់ខេត្តពោធិ៍សាត់ ដើម្បីទាមទារឱ្យអាជ្ញាធរដោះស្រាយវិវាទដីធ្លីរបស់ពួកគេ នៅចំណុចឃុំអន្លង់ចំបក់ ស្រុកក្រគរ កាលពីព្រឹកថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២១។

លោក យុត សុគន្ធ មានប្រសាសន៍ថា អំឡុងពេលដែលអភិបាលរងខេត្តពោធិ៍សាត់ លោក ចេង ឡៃ និយាយទៅកាន់ប្រជាពលរដ្ឋដោយប្រាប់ថា ពលរដ្ឋខេត្តកំពង់ឆ្នាំងដែលមានដីនៅក្នុងខេត្តពោធិ៍សាត់ មិនអាចអាស្រ័យផលលើដីនោះទៀត រូបលោកបានយកឧបករណ៍មកថតសំឡេងនិងយកសៀវភៅមកកត់ត្រា ប៉ុន្តែត្រូវបានសមត្ថកិច្ចហៅទៅសួរនាំ ហើយបានឆក់យកឧបករណ៍ថតសំឡេងនិងសៀវភៅពីលោក។ លោកថា ៖ «សមត្ថកិច្ចបានហៅខ្ញុំទៅ ហើយបានឆក់យកសៀវភៅ និង Recorder (ឧបករណ៍ថតសំឡេង)ពីខ្ញុំ ហើយបាន

លុបចោលសំឡេងដែលខ្ញុំបានថត ហើយគាត់បានព្យាយាមមិនឱ្យយើងថតទៅទៀត»។ លោក សុគន្ធ បន្តថា ក្រៅពីឆក់សម្ភាររបស់លោកហើយ សមត្ថកិច្ចក៏បានហាមលោកមិនឱ្យថតផ្តិតយករូបភាពផ្សេងៗពាក់ព័ន្ធនឹងទិដ្ឋភាពតវ៉ានោះ ទោះបីជារូបលោកបានប្រាប់ទៅសមត្ថកិច្ចថា ខ្លួនជាអ្នកយកព័ត៌មានរួចហើយក៏ដោយ។ សមត្ថកិច្ចបានប្រគល់ឧបករណ៍ថតសំឡេងនិងសៀវភៅមកឱ្យលោកវិញ ក្រោយពេលជំនួបរវាងអភិបាលរងខេត្ត លោក ចេង ឡៃ ជាមួយពលរដ្ឋ ត្រូវបានបញ្ចប់។

ករណីដូចគ្នានេះបានកើតមានលើអ្នកសារព័ត៌មានមួយរូបទៀតគឺលោក កែវ រតនា ចាងហ្វាងសារព័ត៌មាន TN Hotnews កាលពីព្រឹកថ្ងៃទី ១១ខែឧសភា ឆ្នាំ ២០២១ នៅខណៈពេលដែលរូបលោកចុះយកព័ត៌មានអំពីករណីជម្លោះដីធ្លីមួយកន្លែងស្ថិតនៅក្នុងភូមិទី ៧ សង្កាត់ក្បាលត្រាច ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដោយប្រជាពលរដ្ឋដែលមានជម្លោះដីធ្លីចំនួន៣៧គ្រួសារ ផ្ទុះការតវ៉ា និងស្នើសុំយុត្តិធម៌ ខណៈតុលាការខេត្តកំពង់ឆ្នាំងសម្រេចឱ្យលោក លី ផេង ឈ្នះក្តី និងប្រកាសសាលក្រម កាត់ដីជាង៥ហិតាទៅឱ្យលោក លី ផេង និងឆ្វៀលដី៨១៧៨ការ៉េ របស់ប្រជាពលរដ្ឋទុក។

លោក កែវ រតនា មានប្រសាសន៍ថា នៅខណៈពេលដែលរូបលោកកំពុងចុះយកព័ត៌មានអំពីករណីជម្លោះដីធ្លីខាងលើ មានបុគ្គលឈ្មោះ លន់ ឡេង មានតួនាទីជាកងអង្គរក្ស និងជាអ្នកចេញមុខកាងឱ្យភាគីមានជម្លោះដីធ្លីជាមួយប្រជាពលរដ្ឋ បានគំរាមនិងរំខានដល់ការងារចុះយកព័ត៌មានរបស់លោក ដោយបានបញ្ជាឱ្យសមត្ថកិច្ចតាមរូបលោក រុញច្រាន និងចង់វាយរូបលោកថែមទៀត តែមានក្រុមប្រជាពលរដ្ឋនៅទីនោះ និងអាជ្ញាធរជួយឃាត់ទាន់ពេល។

យើងខ្ញុំចាត់ទុកការប្រមាថ និង ការរំខានទាំងឡាយមកលើអ្នកសារព័ត៌មានដូចដែលបានរៀបរាប់ខាងលើថា ជាការគំរាមកំហែង រំលោភសិទ្ធិសេរីភាព និងបំពានដល់ការអនុវត្តតួនាទីរបស់អ្នកសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ។

នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) លោក ណុប វី មានប្រសាសន៍ថា ៖ **«សកម្មភាពទាំងអស់នោះ គឺជាការគំរាមកំហែង ជ្រៀតជ្រែក និងបំពានដល់ការអនុវត្តតួនាទីភារកិច្ច និងសិទ្ធិសេរីភាពរបស់អ្នកសារព័ត៌មាន ហើយវាធ្វើឱ្យប៉ះពាល់ដល់ឆន្ទៈរបស់ប្រមុខដឹកនាំរដ្ឋាភិបាលក្នុងការយកអ្នកសារព័ត៌មានជាដៃគូមិនអាចខ្វះបានរបស់រដ្ឋាភិបាល»។**

ជាថ្មីម្តងទៀត យើងសូមអំពាវនាវដល់រាជរដ្ឋាភិបាល គួរមានវិធានការទៅលើមន្ត្រីទាំងឡាយណាដែលបំភិតបំភ័យ គំរាមកំហែង និងរំខានដល់កិច្ចការអ្នកសារព័ត៌មាន ដើម្បីធានាអំពីប្រសិទ្ធភាពនៃការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ និងការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។

ជាមួយគ្នានេះផងដែរ យើងខ្ញុំក៏អំពាវនាវទៅដល់បងប្អូនអ្នកសារព័ត៌មានទាំងអស់ ពិសេសអ្នកសារព័ត៌មានអនឡាញមួយចំនួន ដែលបាននិងកំពុងបន្តធ្វើសកម្មភាពមិនសមរម្យប្រាសចាកពីក្រមសីលធម៌ និង

គោលការណ៍វិជ្ជាជីវៈអ្នកសារព័ត៌មាន ដូចជាករណីប្រើបណ្ណ ឬកាតអ្នកសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ទៅគំរាមសម្លុត និងជំរិតទារប្រាក់ពីប្រភពជាថ្នូរនឹងការចុះផ្សាយ ឬមិនចុះផ្សាយព័ត៌មានជាដើម សូមពង្រឹងការអនុវត្តនិងគោរពក្រមសីលធម៌ និងវិជ្ជាជីវៈអ្នកសារព័ត៌មានឱ្យបានខ្ជាប់ខ្ជួន ដើម្បីចូលរួមលើកកម្ពស់គុណតម្លៃ និងកិត្តិយសរបស់អ្នកសារព័ត៌មាន៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
ទូរសព្ទលេខ៖ ០១២ ៥១៩ ២៦១
អ៊ីមែល៖ ed@camboja.net

ស្ថាប័ន និង បណ្តាញដែលបានចូលរួមគាំទ្រសេចក្តីថ្លែងការណ៍នេះមាន៖

1. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
2. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
3. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
4. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)
5. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
6. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)
7. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)